ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៣៦៣/១៧ ព.ណ.កសប

ភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៧

**ជម្រាបមក**

**លោក/លោកស្រីប្រធានក្រុមហ៊ុន យូនីលីវើ (ខេមបូឌា) លីមីធីត**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលម្សៅសាប៊ូសម្រាប់បោកគក់ម៉ាក "VISO" និង "BREEZE" សាប៊ូសម្រាប់ព្យាបាលសក់ និងកក់សក់ម៉ាក "SUNSILK" "CLEAR" និង "DOVE" សាប៊ូសម្រាប់ដុសខ្លួនម៉ាក "LUX" និង "LIFEBUOY" ផលិតផលសម្រាប់ការពារ និងសម្អាតធ្មេញម៉ាក "PEPSODENT" និង "SIGNAL" ផលិតផលសម្រាប់ការពារផ្ទៃមុខ និងសម្អាតផ្ទៃមុខម៉ាក "POND'S" និង "VASELINE" ផលិតផលសម្រាប់លាបការពារស្បែកម៉ាក "CITRA" ផលិតផលតែម៉ាក "LIPTON" គ្រឿងសម្អាងម៉ាក "AVIANCE" ផលិតផលសម្រាប់ប្រើប្រាស់ឲ្យរាងកាយមានក្លិនក្រអូបម៉ាក "REXONA" ផលិតផលសម្រាប់បន្ថែមក្លិនក្រអូបដល់សំលៀកបំពាក់សម្រាប់ការបោកគក់ម៉ាក "COMFORT" និងសាប៊ូសម្រាប់លាងចានម៉ាក "SUNLIGHT" ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **យូនីលីវើ (ខេមបូឌា) លីមីធីត** ។

**យោង:** - មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Unilever N.V. ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៧
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/៧៩៥៦/៩៦ ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/២០៤៣/៩២ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៣៨៧៦៩/១១ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១១
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/២០៦៤១/០៤ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/២០៣៧/៩២ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/២០៣៦/៩២ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/២០៤០/៩២ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/១៣២៥១/០០ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦០៤៥៥/១៦ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/១៣០៦៦/០០ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/១២២២៥/៩៩ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/៨១៤៧/៩៦ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/១២៧៨៨/០០ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៤៥៦៤៤/១៣ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/២០៤១/៩២ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/៥១៧/៩២ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក លេខចុះបញ្ជី KH/២០២៤/៩២ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១២។

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលម្សៅសាប៊ូសម្រាប់បោកគក់ សាប៊ូសម្រាប់ព្យាបាលសក់ និងកក់សក់ សាប៊ូសម្រាប់ដុសខ្លួន ផលិតផលសម្រាប់ការពារ និងសម្អាតធ្មេញ ផលិតផលសម្រាប់ការពារផ្ទៃមុខ និងសម្អាតផ្ទៃមុខ ផលិតផលសម្រាប់លាបការពារស្បែក ផលិតផលតែ គ្រឿងសម្អាង ផលិតផលសម្រាប់ប្រើប្រាស់ឲ្យរាងកាយមានក្លិនក្រអូប ផលិតផលសម្រាប់បន្ថែមក្លិនក្រអូបដល់សំលៀកបំពាក់សម្រាប់ការបោកគក់ និងសាប៊ូសម្រាប់លាងចានពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **យូនីលីវើ (ខេមបូឌា) លីមីធីត** ដែលទទួលបានពីក្រុមហ៊ុន Unilever N.V. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ មានសុពលភាពរយៈពេល ០២(ពីរ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Unilever N.V. ដែលជាម្ចាស់ម៉ាក ។

ចាប់ពីរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ អ្នកទទួលសិទ្ធិស្របច្បាប់ មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងចំពោះទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្ត ជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ុក-ប្រុជា**

<u>ចម្លងជូន:</u>
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ